ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១៥០១ ប្រក

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តក្នុងការចាត់ចែង ដំណើរការនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្ត ឱ្យទទួលខុសត្រូវក្នុងការចាត់ចែងដំណើរការនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ ២.-**

អភិបាលរាជធានី ខេត្ត មានសិទ្ធិអំណាចក្នុងការចាត់តាំងមន្ត្រីឱ្យធ្វើជាអធិបតីនៃការប្រជុំលើកដំបូង របស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។ មន្ត្រីដែលចាត់តាំងទាំងនោះ រួមមាន អភិបាលរង នៃគណៈអភិបាល រាជធានី ខេត្ត អភិបាល អភិបាលរង នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាល នាយករងរដ្ឋបាល នាយកទីចាត់ការ នាយករងទីចាត់ការ នៃសាលារាជធានី ខេត្ត និងនាយករដ្ឋបាល នាយករងរដ្ឋបាល នៃសាលា ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៣.-**

អភិបាលរាជធានី ខេត្ត និងមន្ត្រីដែលត្រូវបានចាត់ឱ្យធ្វើជាអធិបតីនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិថ្មី ត្រូវអនុវត្តតួនាទី និងភារកិច្ចឱ្យបានសមស្របទៅតាមសេចក្តីណែនាំស្តីពីការរៀបចំការប្រជុំ លើកដំបូង ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកាសឈ្មោះ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ព្រមទាំងណែនាំអំពីការចាប់ផ្តើមបំពេញការងារបន្ទាប់ពីកិច្ចប្រជុំលើកដំបូង។

**ប្រការ ៤.-**

ប្រកាសលេខ៤៤៦ ប្រក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើ ប្រតិភូកម្មអំណាចដល់អភិបាលគ្រប់ខេត្ត ក្រុង ក្នុងការចាត់ចែងដំណើរការកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នង ការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធចំណុះក្រសួង មហាផ្ទៃ ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួល បន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៧*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងមុខងារសាធារណៈ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *អគ្គលេខាធិការរបស់រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*

*(ដើម្បីជូនជ្រាប )*

- *ដូចប្រការ ៥*
- *ឯកសារ កាលប្បវត្តិ*